ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

| |
|---|
| តុលាការខេត្តបាត់ដំបង |
| សំណុំរឿងព្រហ្មទណ្ឌ |
| លេខ ៤៥ ចុះថ្ងៃទី ១៥ |
| ខែ មករា ឆ្នាំ ២០០៤ |
| សាលក្រម |
| លេខ ៤០ ក ចុះថ្ងៃទី ២០ |
| ខែ កុម្ភៈ ឆ្នាំ ២០០៦ |

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការខេត្តបាត់ដំបង

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តបាត់ដំបង នៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

ចៅក្រមជំនុំជំរះ

លោក [redacted] ជាប្រធានតុលាការខេត្តបាត់ដំបង

តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារង

ក្រឡាបញ្ជីសវនាការ

លោក [redacted]

ដើម្បីជំនុំជំរះរឿងក្តីព្រហ្មទណ្ឌលេខ ៤៥ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៤ ដែលមានជនជាប់ចោទ :

១-ឈ្មោះ អ ឆ ភេទប្រុស អាយុ ៥៣ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មានរបររកស៊ីធ្វើ ស្រែចំការ មានទីកន្លែងកំណើតនៅភូមិលោក ឃុំសន្លុង ស្រុកទ្រាំង ខេត្តតាកែវ មានកំរិតវប្បធម៌ថ្នាក់ទី ៥ចាស់ កាន់សាសនាព្រះពុទ្ធ មានទីលំនៅសព្វថ្ងៃនៅភូមិរូង ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ មានប្រពន្ធឈ្មោះ ព រ (រ) មានកូន ០៥នាក់ មានឪពុក ឈ្មោះ ឧ ឧ (ស) មានម្តាយឈ្មោះ អ ស (ស) ទោសពីមុន *គ្មាន* ក្រៅឃុំ ។

ត្រូវចោទពីបទ **ជេរប្រមាថ** តាមបញ្ញត្តិមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ប្រព្រឹត្តនៅភូមិត្រាវជូ ឃុំស៊ីរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៣ ។

ជនរងគ្រោះឈ្មោះ **អ ស** ហៅ អ ភេទប្រុស អាយុ ៣៥ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិត្រាវជូ ឃុំស៊ីរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ។

សុំដកបណ្តឹងការទាមទារសំណងជម្ងឺចិត្ត ពីជនជាប់ចោទឈ្មោះ **អ ឆ** ។

## ការប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ

កាលពីថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៣ នៅភូមិត្រាវជូ ឃុំស៊ីរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ជនជាប់ចោទឈ្មោះ **អ ឆ** បានជេរប្រមាថទៅលើ ជនរងគ្រោះឈ្មោះ **អ ស** ហៅ អ ថា អាចុយម្រាយអាណាធ្វើបេង អញបាញ់ហ្វៃង ចុយម្រាយឥឡូវ អាចុយម្រាយហ្វៃងខ្លាំង អញបាញ់ហ្វៃងចុយម្រាយឥឡូវនឹងបាន

យកកាំភ្លើងផ្ទុកដាក់ភ្លើងថ្លៃដេញបាញ់ជនរងគ្រោះ ហើយជនរងគ្រោះរត់គេចខ្លួនបាត់ ។

តាមរបាយការណ៍ព្រឹត្តិហេតុចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៣ របស់ប៉ុស្តិ៍នគរបាលមានជ័យ បញ្ជាក់ថា កាលពីយប់ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៣ វេលាម៉ោង ២០ និង ៣០នាទី នៅចំណុចក្រុមទី១១ ភូមិត្រាវជ្វ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង មានករណីប្រើប្រាស់អាវុធខុសច្បាប់ ជាកាំភ្លើងកិបថ្លៃ ប្រើប្រាស់ដោយឈ្មោះ អ ម បានដេញបាញ់ទៅលើឈ្មោះ អ ស តែមិនបណ្តាលអោយមានរបួសទេ ព្រោះជនរងគ្រោះរត់គេច ខ្លួនបាត់ ។

## នរៈពេលសវនាការ

តាមការអានចម្លើយឈ្មោះ អ ម ជាជនជាប់ចោទបញ្ជាក់ថា កាលពីថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៣ ពេលព្រលប់ខ្លួនបររទេះមកដល់ចំណុចភូមិត្រាវជ្វ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ត្រង់ផ្លូវមុខផ្ទះឈ្មោះ អ ស ជាដើមបណ្តឹង រទេះរបស់ខ្លួនបានទាក់បង្គោលរបង ដែលបោះសង្ខាងផ្លូវទុកតែប្រហែល ០២ម៉ែត្រ បណ្តាលអោយដួលរបងខាងស្តាំ ស្រាប់តែឈ្មោះ អ ស និង ប្រពន្ធស្រែកជេរខ្លួន ខ្លួនក៏ចុះពីលើរទេះកាន់ជន្ទល់រទេះ និង ពូថៅ ព្រោះខ្លួនឃើញឈ្មោះ អ ស កាន់កាំបិតថ្លៃ ហើយខ្លួនគំរាមថា ហ្អែងហ៊ានចូលអញបាញ់ ។ ការពិតខ្លួនគ្មានកាំភ្លើងទេ ។ ឈ្មោះ អ ស មិនហ៊ានចូលមកទេ ខ្លួនក៏បររទេះចេញពីទីនោះទៅ ។

-ឈ្មោះ អ ស ជាជនរងគ្រោះ និង ជាដើមបណ្តឹងឆ្លើយថា នៅថ្ងៃកើតហេតុវេលាម៉ោង ០៨យប់ ឈ្មោះ អ ម បររទេះមកដល់ត្រង់ផ្លូវមុខផ្ទះរបស់ខ្លួន ទើសបង្គោលដែលដាំនៅសង្ខាងផ្លូវ គាត់បានជេរមកលើខ្លួនថា អាចុយម្រាយហ្អែងខ្លាំង បាញ់ហ្អែងចុយម្រាយ ហើយជេរពាក្យដដែលនេះប្រហែល ១ម៉ោង ក្រោយមកបានយកកាំភ្លើង ផ្ទុកកៃថ្លៃ ដេញបាញ់ខ្លួន តែមិនបានបាញ់ទេ ព្រោះខ្លួនរត់គេចខ្លួនទាន់ ។ នៅពេលថ្មីៗនេះឈ្មោះ អ ម បានទទួលដីកាកោះរបស់តុលាការអោយចូលសវនាការ បានមកនិយាយអង្វរកខ្លួនសុំទោសខ្លួនដឹងពីកំហុសរបស់គាត់ ។ ដោយក្រោយពេលកើតហេតុនេះឈ្មោះ អ ម មិនដែលមករករឿងខ្លួនទៀងនោះ ខ្លួនសុំឈប់ប្តឹងលើឈ្មោះនេះទៀត ហើយ ឯសំណងរដ្ឋប្បវេណីក៏ខ្លួនពុំទាមទារដែរ ។

-ឈ្មោះ យ ត ជាសាក្សីឆ្លើយថា នៅថ្ងៃកើតហេតុម៉ោងប្រហែល ០៨ និង ៣០នាទីយប់ ឈ្មោះ អ ម បររទេះមកទាក់ព្រែកនឹងបង្គោលរបងនៅមុខផ្ទះឈ្មោះ អ ស ហើយស្រែកជេរថា ហ្អែងខ្លាំងអញបាញ់ហ្អែងឱ្យងាប់អាចុយម្រាយ អញបាញ់អោយងាប់ ហើយបានយកកាំភ្លើងមកដេញបាញ់ឈ្មោះ អ ស តែមិនបានបាញ់ទេ ព្រោះឈ្មោះ អ ស គេចខ្លួនបាត់ ។ កាំភ្លើងនោះខ្លួនមិនដឹងថា កាំភ្លើងអ្វីទេ ព្រោះយប់ខ្លួនងងឹតមើលមិនច្បាស់ ។

-ឈ្មោះ ៥ ខ ជាសាក្សីឆ្លើយថា រឿងហេតុនៅកន្លែងកើតហេតុ ខ្លួនមិនបានដឹងទេ ។ គ្រាប់តែដឹងថា នៅថ្ងៃក្រោយពេលកើតហេតុ ខ្លួនត្រូវមេភូមិអោយធ្វើសំបុត្រហៅឈ្មោះ អ ម ហើយយកទៅប្រគល់អោយឈ្មោះនោះ ។ នៅពេលខ្លួនទៅដល់ផ្ទះគាត់ ប្រាប់ពីការអញ្ជើញនោះ ឈ្មោះ អ ម ប្រាប់ថា គាត់មិនបានមកដោះស្រាយនៅភូមិទេ ។

-ឈ្មោះ ត សរ ជាសាក្សីពន្លឺឆ្លើយថា នៅថ្ងៃកើតហេតុខ្លួនឮឈ្មោះ អ ម ជេរប្រមាថមកដល់ប្តីរបស់ខ្លួនថា អាចុយម្រាយហ្អែងរកស៊ីបិទផ្លូវ បានតែបាញ់ហ្អែងចុយម្រាយ ។ ពេលនោះប្តីរបស់ខ្លួនមិនបានជេរតបតទៅវិញទេ គ្រាន់តែថា គ្មានអ្នកណាគេបិទផ្លូវទេ ស្រាប់តែឈ្មោះ អ ម ដេញបាញ់ប្តីរបស់ខ្លួនដោយកាំភ្លើងផ្ទុក ហើយស្រែកថា បាញ់ហ្អែងអោយចុយម្រាយ បាញ់ហ្អែងអោយងាប់ តែមិទបានបាញ់ទេ ព្រោះប្តីខ្លួនរត់គេចបាត់ ។

-តាមការអានចម្លើយឈ្មោះ ខ ឆ ជាសាក្សីបញ្ជាក់ថា នៅយប់កើតហេតុខ្លួននៅផ្ទះរបស់ខ្លួនបានឮសំលេងមាត់ឡូឡាខ្លាំងៗខ្លួនមិនបានមកមើលទេ ព្រោះយប់ងងឹត ។ លុះព្រឹកឡើងខ្លួនដើរមកផ្ទះឈ្មោះ ក ស ដែលនៅជិតផ្ទះឈ្មោះ អ ស ហើយបានសាកសួរទៅឈ្មោះ ក ស ឆ្លើយថា ឈ្មោះ អ ស ទៅត្រាវជូ ហើយរឿងហេតុផ្សេងៗ ទៀតខ្លួនមិនបានដឹងទេ ។

## តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការបញ្ជាក់ថា

-មានភស្តុតាង និង មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ.ឈ្មោះ អ ឃ ពីបទជេរប្រមាថ ប្រព្រឹត្តនៅភូមិត្រាវជូ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៣ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

-តម្កល់បទចោទ និង សុំតុលាការផ្តន្ទាទោសជាក់ពន្ធនាគារលើជនជាប់ចោទកំណត់ពី ០៦ខែ ដល់ ១២ខែ ។

-បានស្តាប់ក្រឡាបញ្ជីអានចម្លើយដោះសាររបស់ជនជាប់ចោទ
-បានស្តាប់ចម្លើយជនរងគ្រោះឆ្លើយអោយការណ៍
-បានស្តាប់ចម្លើយអោយការណ៍របស់សាក្សី សាក្សីពន្លឺ
-បានស្តាប់ការសួរដេញដោល ចោទឆ្លើយតទល់
-បានពិនិត្យ កំណត់ហេតុ ឯកសារ ភស្តុតាងទានា
-បានស្តាប់សេចក្តីសន្និដ្ឋានចោទប្រកាន់ទោសរបស់តំណាងអយ្យការ
-បានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការខេត្តបាត់ដំបង
## យល់ឃើញថា

-ពិតជាកើតមាននូវអំពើជេរប្រមាថ នៅភូមិត្រាវជូ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៣ ។

-អំពើជេរប្រមាថ ដែលកើតមាននៅទីកន្លែង និង ពេលវេលាដូចខាងលើពិតជាប្រព្រឹត្តឡើងដោយឈ្មោះ អ ឃ បានជេរប្រមាថនូវពាក្យអសុរសជាច្រើនចំពោះឈ្មោះ អ ស ហៅ អ ថា "កណ្តុយម៉ែអាចុយម្រាយ អាណាធ្វើរបង អញបាញ់ហ្វៃងអោយចុយម្រាយឥឡូវ អាចុយម្រាយហ្វៃងខ្លាំងបាញ់ហ្វៃងឱ្យចុយម្រាយ" និង បានយកកាំភ្លើងឆ្នុកច្នៃដេញរកបាញ់ និង ឃ្លាំមើលឈ្មោះ អ ស រហូតដល់ភ្លឺប្រាកដមែន ។

-អំពើដែលជនជាប់ចោទបានប្រព្រឹត្តនៅទីកន្លែង និង ពេលវេលាដូចខាងលើនេះ មានធាតុផ្សំគ្រប់គ្រាន់ជាបទជេរប្រមាថ ដូចមានបញ្ញត្តិក្នុងមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ជនជាប់ចោទជាសមត្ថជនមានអាយុ ៥៥ឆ្នាំ មានស្មារតីជានាល្អ គាត់បានជេរ និង ប្រមាថដោយចំពោះឈ្មោះ អ ស ប្រាកដមែន ។

## យល់ឃើញថា

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទ ពីបទជេរប្រមាថ ប្រព្រឹត្តនៅទីកន្លែង និង ពេលវេលា

ដូចការចោទប្រកាន់របស់អយ្យការប្រាកដមែន ។

## ភស្តុតាងដាក់បន្ទុកមាន

-ចម្លើយអោយការណ៍របស់ជនរងគ្រោះឈ្មោះ អ ស បានឆ្លើយបញ្ជាក់យ៉ាងច្បាស់អំពីអំពើ ដែលជនជាប់ចោទបានជេរ និង ប្រមាថខ្លួនថា "កណ្តួយម៉ែអាចុយម្រាយ អាណាធ្វើរបងអញបាញ់ហ្មែងអោយចុយម្រាយ ឥឡូវអាចុយម្រាយហ្មែងខ្លាំងបាញ់ហ្មែងអាចុយម្រាយ" និង បានយកកាំភ្លើងឆ្នុកថ្មៃដេញរកបាញ់ និង ឃ្លាំមើលឈ្មោះ អ ស រហូតដល់ភ្លឺប្រាកដមែន ចម្លើយនេះវាស៊ីសង្វាក់គ្នាទៅនឹងចម្លើយអោយការណ៍របស់សាក្សីពន្លឺឈ្មោះ ភ សរ និង សាក្សីឈ្មោះ ៥ ត, ភ, ស ដែលបានឆ្លើយអោយការណ៍ ។

-ចម្លើយអោយការរបស់សាក្សីឈ្មោះ ឃ ត បានឆ្លើយអោយការណ៍ថា ខ្លួនបានឮឈ្មោះ អ ហ ជេរឈ្មោះ អ ស ថា ហ្មែងខ្លាំងយកកាំភ្លើងបាញ់ហ្មែងអោយងាប់ និង មួរបេសន្ទុះខ្លួនបានឃើញឈ្មោះ ហ បានកាំភ្លើងមករកបាញ់ឈ្មោះ អ ស មែន ដោយគាត់និយាយថា បាញ់ហ្មែងអោយងាប់ ។

-ជនជាប់ចោទបានឆ្លើយដោះសារថា "ខ្លួនមិនបានជេរ និង ប្រមាថឈ្មោះ អ ស ទេ គឺខ្លួនពិតជាមានទំនាស់ជាមួយឈ្មោះ ស ខ្លួនមានកាំភ្លើងឆ្នុកថ្មៃ ០១ដើមនៃទុកបាញ់សត្វ នេះសបញ្ជាក់អោយឃើញថា ឈ្មោះ ហ ពិតជាបានជេរប្រមាថឈ្មោះ ស មែន ។ ម៉្យាងទៀតឈ្មោះ អ ហ បានទទួលដីកាបង្គាប់អោយចូលខ្លួនមកសវនាការហើយ តែមិនព្រមចូលខ្លួនមកបញ្ជាក់ថា ជនជាប់ចោទគ្មានភស្តុតាងដោះសារឡើយ ។

-កំណត់ហេតុ ឯកសារ ភស្តុតាងនានា ធ្វើឡើងដោយនគរបាលយុត្តិធម៌ ។

## យល់ឃើញថា

-ជនជាប់ចោទមានលំនៅដ្ឋាន មានមុខរបរក្រុមគ្រួសារត្រឹមត្រូវច្បាស់លាស់ ហើយគាត់ជាប់ចោទពីបទមជ្ឈិម ជាហេតុអាចអោយតុលាការយកមកពិចារណាជាស្ថានទម្រាលទោស និង អោយគាត់ទទួលទោសព្យួរបាន ។

-ឈ្មោះ អ ស ប្តឹងសុំដកពាក្យបណ្តឹងទារសំណងជម្ងឺចិត្តពីជនជាប់ចោទ ធ្វើឡើងបានត្រឹមត្រូវតាមទម្រង់ច្បាប់ និង ដោយស្ម័គ្រចិត្តពិប្រាកដ ។

## ហេតុដូច្នេះតុលាការវិនិច្ឆ័យសេចក្តី

១-ផ្តន្ទាទោសឈ្មោះ អ ហ ដាក់ពន្ធនាគារកំណត់ ០៦ខែគត់ តែទោសនេះអោយឈ្មោះ អ ហ ទទួលទោសព្យួរ ដោយកំណត់រយៈពេលសាកល្បង ០៥ឆ្នាំ គិតចាប់ពីក្រោយពេលកាត់សេចក្តីនេះតទៅ ពីបទ ជេរប្រមាថ ប្រព្រឹត្តនៅភូមិត្រាវជ្ជ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៣ ។

បទល្មើសព្រហ្មទណ្ឌ ទណ្ឌកម្ម និង ការផ្តន្ទាទោស មានបញ្ញត្តិក្នុងមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ និង បទបញ្ញត្តិមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដែលបានប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/០១០២/០១៤ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ។

២-សាលក្រមនេះ ប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ ។ ទុករយៈពេលប្តឹងទាស់ និង បើក
ផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមជំនុំជំរះ**

[redacted] [redacted]

---

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់បកអ្នកអនុវត្តសាលក្រមអោយសំរេច តាមសាលក្រមនេះ និង អោយអាជ្ញាធរគ្រប់តំណែង គ្រប់ជាន់ថ្នាក់ ជួយអនុវត្តអោយបានសំរេច បើមានសំណូមពរ ត្រឹមត្រូវតាមច្បាប់ ។

*បាត់ដំបង.ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៦*
**ជ.ក្រឡាបញ្ជីសវនាការ**

**បានឃើញ**
*បាត់ដំបង.ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៦*
**ប្រធានតុលាការខេត្ត**

[redacted]